អង្គភាពសវនកម្មផ្ទៃក្នុង

# អត្ថបទប្រចាំខែ

លេខ ១៩/២៣ ចេញផ្សាយ ខែកក្កដា ឆ្នាំ២០២៣

## សារៈសំខាន់នៃផែនការប្រតិបត្តិការ

ដើម្បីឱ្យស្ថាប័នមួយដំណើរការទៅបានជោគជ័យរយៈពេលវែង ចាំបាច់ត្រូវមានប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងមួយដ៏រឹងមាំ ដែលក្នុងនោះការរៀបចំផែនការប្រតិបត្តិការជាផ្នែកមួយដ៏សំខាន់ក្នុងការជួយស្ថាប័នលើការត្រួតពិនិត្យនិងផ្ទៀងផ្ទាត់ការទទួលខុសត្រូវ លើសកម្មភាពការងាររបស់ខ្លួនប្រកបដោយប្រសិទ្ធភាព ប្រសិទ្ធផល និងភាពសន្សំសំចៃ។ ស្ថាប័នដែលគ្រប់គ្រងប្រតិបត្តិការបានល្អ អាចជួយទប់ស្កាត់និងគ្រប់គ្រងហានិភ័យ ព្រមទាំងជួយកសាងកេរ្តិ៍ឈ្មោះរបស់ស្ថាប័ន និងបង្កើនទំនុកចិត្តដល់សាធារណជន។




ការរៀបចំផែនការប្រតិបត្តិការ ជាមុខងារនៃការគ្រប់គ្រងដែលទាក់ទងទៅនឹងការកំណត់គោលដៅ សម្រាប់ការអនុវត្តការងាររបស់ស្ថាប័ននៅពេលអនាគត និងការសម្រេចចិត្តទៅលើការងារ និងធនធានដែលត្រូវការប្រើប្រាស់ដើម្បីសម្រេចគោលដៅព្រមទាំងទទួលបានលទ្ធផលជាក់លាក់ណាមួយទៅតាមពេលកំណត់។

ផែនការប្រតិបត្តិការ ត្រូវរៀបចំឡើងប្រកបដោយភាពច្បាស់លាស់ ដោយគួរសបញ្ជាក់ពីទំនួលខុសត្រូវរបស់បុគ្គលទទួលបន្ទុក ក្នុងគោលបំណងសម្រេចផែនការ ឬដំណើរកិច្ចការងារប្រចាំថ្ងៃរបស់ស្ថាប័ន។ ក្នុងនោះផងដែរ ប្រធានស្ថាប័នត្រូវធានាថាថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់ដែលចូលរួមអនុវត្តផែនការរបស់ស្ថាប័ន បានយល់ច្បាស់អំពីអ្វីដែលស្ថាប័នត្រូវធ្វើក្នុងពេលបច្ចុប្បន្ន និងក្នុងពេលអនាគត ស្របតាមផែនការរបស់ស្ថាប័ន ដើម្បីសម្រេចបាននូវផែនការអាទិភាពដែលបានកំណត់ទុក។

សារៈសំខាន់នៃផែនការប្រតិបត្តិការ ផ្តល់នូវសារៈសំខាន់ដល់បុគ្គលអនុវត្តសកម្មភាពដូចជា៖

**ក. ផ្តល់នូវទិសដៅ**៖ ការធ្វើផែនការជាចំណុចសំខាន់សម្រាប់ជួយដល់បុគ្គលទទួលបន្ទុកអនុវត្តសកម្មភាពការងារដឹងច្បាស់ពីគោលដៅដែលពួកគេចង់សម្រេចបាននៅក្នុងផែនការ។

**ខ. សម្របសម្រួល**៖ ការធ្វើផែនការអាចភ្ជាប់រាល់ការប្រឹងប្រែងទាំងអស់របស់បុគ្គលទទួលបន្ទុក ក្នុងការអនុវត្តការងារដើម្បីធ្វើការសម្របសម្រួលជាមួយភាគីពាក់ព័ន្ធ។

**គ. ផ្តល់នូវខ្នាតគំរូ**៖ ការធ្វើផែនការអាចឱ្យអ្នកដឹង ឬស្គាល់ពីទំហំនៃប្រតិបត្តិការការងារ ដែលអាចជួយអ្នកក្នុងការកំណត់ និងផ្តល់នូវខ្នាតគំរូជាក់លាក់ណាមួយក្នុងផែនការប្រតិបត្តិការ។

**ឃ. បញ្ជាក់**៖ ការធ្វើផែនការអាចផ្តល់នូវភាពច្បាស់លាស់នៃគោលបំណង សកម្មភាព និងធនធានដែលអ្នកអនុវត្តត្រូវដឹងមុននឹងអនុវត្តការងារ។

**ង. រៀបចំ**៖ ក្នុងពេលដែលបុគ្គលទទួលបន្ទុករៀបចំនូវផែនការជូនថ្នាក់ដឹកនាំ បុគ្គលទទួលបន្ទុកគួរតែគិតគូរដល់កត្តាមួយចំនួនដែលអាចផ្តល់ជាការប្រឈមមុខនឹងបញ្ហា។ កត្តាដែលជះឥទ្ធិពលរួមមានកត្តាខាងក្នុងស្ថាប័ន កត្តាខាងក្រៅស្ថាប័ន និងកត្តាជះឥទ្ធិពលប្រយោល។

**ច. ជំរុញ**៖ ការធ្វើផែនការ បានលើកទឹកចិត្តឱ្យទទួលជ័យជំនះលើការអនុវត្តផែនការ។

ជារួម ការរៀបចំផែនការប្រតិបត្តិការពិតជាមានសារៈសំខាន់សម្រាប់ស្ថាប័នមួយព្រោះផែនការប្រតិបត្តិការនឹងបង្ហាញពីសកម្មភាពការងារដែលនឹងត្រូវអនុវត្ត ដើម្បីសម្រេចនូវចក្ខុវិស័យ និងគោលបំណង និងគោលដៅរបស់ស្ថាប័ន។

**អត្ថបទ**៖ កញ្ញា **វ៉េត បុប្ផាវ័ត្ត**

**ឯកសារយោង**៖ *ឧត្តមានុវត្តន៍នៃការគ្រប់គ្រងប្រតិបត្តិការរបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃអ.ស.ហ.*